# ស័ង្ខសិល្បជ័យ

កាលពីព្រេងនាយកន្ទងយូរយារមកហើយ មានស្ដេចមួយអង្គទ្រង់ព្រះនាមកុត្តរាជ សោយរាជនៅបញ្ចាលបុរី។ ទ្រង់ជាស្ដេចដែលមានអំណាចរឹទ្ធីបារមីលើសអស់ក្សត្រផង នានាសព្វនគរ។ ទ្រង់មានមហេសីមួយអង្គព្រះនាមសុមន្ទាទេវី ដែលមានរូបឆោមលោមពណ៌ល្អបំផុត ព្រមទាំងចរិយាសមសួស្ដីធ្វើឲ្យទ្រង់សព្វព្រះទ័យជាងគេ ហើយទុកជាច្បងក្នុងចំណោមស្រីស្នំទាំង១៦០០០នាក់ផង។ ទ្រង់មានបុត្រាមួយអង្គ ព្រះនាមសេនាកុត្តរាជ លុះអំឡុងយូរទៅទ្រង់បានបង្កើតបុត្រីមួយអង្គ ដែលមានរូបឆោមលោមពណ៌យ៉ាងស្រស់សោភា ព្រះនាមកេសរសុមន្ទា។ ព្រះអង្គកុត្តរាជសព្វព្រះទ័យនឹងបុត្រទាំងពីរណាស់ តែងនាំបុត្រទៅកំសាន្តនៅឧទ្យានស្រះស្រង់ពុំដែលមានលោះថ្ងៃឡើយ។

លុះចំណេរតមក ព្រះអង្គកុត្តរាជទ្រង់ប្រឈួន។ ទ្រង់ហៅរាជបុត្រទាំងពីរមកផ្ដែផ្ដាំថា:

ហៃចៅសេនា កុត្តរាជពុំផា សម្លាញ់បិតា
កូនអើយជម្ងឺ វែងឈឺខ្លោចផ្សា ម្យ៉ាងព្រះបិតា ពុំរស់នៅបាន។
កូនអើយបើបិ តាក្ស័យជីវី អង្គអន្តរធាន
សូន្យសោះទៅណា បិតាមែនមាន តែបាបុត្របាន ប្រុសជាតិជាច្បង។
ចូរចៅបេតី រក្សាជននី នូវប្អូនស្នេហ៍ស្នង
ឥតនឹងបិតា កំព្រាហើយហោង មានបាស្ងួនគ្រង ស្មើឪពុកសោត។
ទោះបីប្អូនខុស ផ្ដាំផ្ដងលើសលប់ កុំបាក្រេវក្រោធ
ទ្រគោះពាក្យរឹង ខេខឹងពិរោធ បាអត់ទោសសោត អាសូរប្អូនណ៎ា។
រីអស់រាស្ត្ររដ្ឋ រម្យរាជសម្បត្តិ អាពុកឲ្យបា
ឯងអាចសេពសោយ រាជ្យដោយសុច រិតទសធម្មា ជាច្បាប់ប្រពៃ។
ធម្មតាមហាក្សត្រ ដោយរាជ្យសម្បត្តិ អម្បូរថ្លៃថ្លៃ
ឲ្យដឹងបាបបុណ្យ ទោសគុណផងនៃ ដឹងទុក្ខរាស្ត្រត្វ កំឡុងជានី។

អត្ថបទដោយ៖ កញ្ញា មាស សុភាព

*ផ្តែផ្តាំស្រេចដល់ត្រឹមនេះ ព្រះអង្គកុត្តរាជទ្រង់ក៏សោយទីវង្គតរលត់ជីវីសោះសូន្យបាត់ទៅ។ អង្គក្សត្រទាំងបីអង្គ ទ្រង់ព្រះកន្សែងសោយសោកយ៉ាងខ្លាំង។ អស់មន្ត្រីស្រីស្នំក្រមការទាំងអស់ខ្សឹកខ្សួលអួលណែនក្នុងឱរានឹងវាចារមិនបាន។ លុះធ្វើពិធីថ្វាយព្រះភ្លើងរួចហើយ អង្គក្សត្រសេនាកុត្តរាជ ទ្រង់ឲ្យជាងសាងសង់ព្រះចេតិយដែលមានរចនាក្បាច់ក្បូរបិទមាសយ៉ាងល្អប្រណិត ដើម្បីដាក់តម្កល់ព្រះធាតុ។ បន្ទាប់ពីរៀបចំបញ្ចុះព្រះធាតុរួចហើយ ព្រះមាតាសុមន្ទាទេវីព្រមទាំងមន្ត្រីអាមាត្យទាំងអស់ ក៏រៀបចំពិធីអភិសេករាជបុត្រសេនាកុត្តរាជឡើងគ្រងរាជ្យសម្បត្តិគ្រប់គ្រងអស់អាណាប្រជានុរាស្ត្រ ទ្រង់មានរិទ្ធិអំណាចខ្លាំងក្រៃ ប្រជារាស្ត្រសឹងបានសុខសាន្តទូទាំងនគរ។ ព្រះអង្គសេនាកុត្តរាជសោយរាជ្យលុះអំឡុងយូរទៅ ក៏ទ្រង់ព្រះចិន្តាថា អនុជប្អូនអង្គអញពេលនេះនាងធំពេញរូបរាងហើយ រូបសម្បត្តិល្អសមសួស្តី អញអាណិតប្អូនណាស់...។ ទ្រង់ព្រះចិន្តារួចហើយ ទ្រង់បានត្រាស់ហៅព្រាហ្មណ៍ហោរាមក ដើម្បីគន់គូរមើលថាតើអនុជមានវាសនាយ៉ាងណាបានស្វាមីជាក្សត្រ ឬមន្ត្រី ជាសេដ្ឋី ឬក៏រាស្ត្រធម្មតា ចូរព្រាហ្មណ៍ទាយកុំគិត កុំកោតចិត្តអញឡើយនៃ។ ទាយដោយហោរាសាស្ត្រសៃយ ឲ្យទៀងទាត់កាលនេះម្តង។ ស្តាប់បន្ទូលព្រះរាជាហើយ ព្រាហ្មណ៍ក៏ចាប់គន់គូរមើល រួចហើយក៏លើកដៃបង្គំវន្ទាទូលថា បពិត្រក្សត្រក្សាន្តឥស្សរៈ*

*យើងខ្ញុំពិចារណា ដោយហោរាត្រាគំនូរ*
*ព្រះកេតុសូន្យសេសសូរ រាហ៊ូបៀតព្រះលក្ខណា។*
*ច័ន្ទចូលចាប់រាសី ដោគផង់ក្តីមិនសូវជា*
*ព្រះគ្រោះអនុជណា ទំនាយថាសឹងកាចក្តាត់។*
*លុះព្រះជន្មគម្រប់ ប្រាំដណ្តាប់ឆ្នាំទៀតទាត់*
*ហើយព្រះប្អូននឹងព្រាត់ ពីចោមចៅនៃក្សត្រា។*

*អត្ថបទដោយ៖ កញ្ញា មាស សុភាព*

នឹងមានយក្សមួយនៅនាព្រៃព្រឹក្សាមកចាប់យក ព្រះអនុជទៅទុកជាភរិយា...។ ព្រះអង្គសេនាកុត្តរាជ ទ្រង់ព្រះសណ្ដាប់ព្រាហ្មណ៍ហោរាទូលហើយ ទ្រង់ព្រះកន្សែងព្រួយព្រះហរទ័យនឹកអាណិតដល់អនុជជាពន់ពេក។ ទ្រង់យាង ចូលក្រឡាបន្ទំហើយទ្រង់ឲ្យយាងអនុជមក។ ព្រះនាងកេសរសុមន្ទាយាងមកដល់ វន្ទាព្រះរាម។ ព្រះអង្គសេនាកុត្តរាជ យល់អនុជមកដល់ទ្រង់លើកព្រះករកៀកសុរង ទ្រង់ព្រះកន្សែង ហើយទ្រង់មានព្រះបន្ទូលយ៉ាងអួលអាក់: ថាហៃប្អូនមាសតន់ ស្ងួនសំលាញ់មាសបងអើយ។

ថ្ងៃនេះឯងណាថៅ បងឲ្យហៅព្រាហ្មណ៍មកហើយ
មើលគ្រោះប្អូនត្រាណត្រើយ នៅសព្វគ្រោះជន្មវស្សា។
ព្រាហ្មណ៍មើលគ្រោះប្អូនរ័តន៍ ថាកាចក្លាត់ក្រៃពេកណា
នឹងមានចោរយក្សា មួយមកលបលួចយកទៅ។

កណ្ដាលព្រៃជ្រៅដល់ហេមពាន្ត ដើម្បីទុកជាមហេសី។ ឲ្យប្អូនមាសស្នេហា តើកម្មពារវេរាអ្វីឲ្យយើងប្រាស់ព្រាត់គ្នាយ៉ាងដូច្នេះ យើងព្រាត់បិតាហើយមានតែមាតា ពេលនេះប្អូនព្រាត់ប្រាស់ទៅ តើបាននរណានឹងថែរក្សាមាតាឲ្យដូចប្អូន...។ លុះរយៈពេលកន្លងទៅ មានថ្ងៃមួយព្រះនាងកេសរសុមន្ទានឹកអផ្សុកក្នុងព្រះកាយ ក៏ឡើងទៅក្រាបបង្គំព្រះរាម ដើម្បីសុំចេញទៅលេងឯឧទ្យានឋាននាយ។ ព្រះអង្គសេនាកុត្តរាជមានបន្ទូលថា: "ហៃប្អូនមាសមិត្ត គ្រោះនាងកាចណាស់ចូរកុំគិតងាយព្រលឹងបងអើយ ក្រែងគ្រោះមកដល់ នេះបើច្បាំងនឹងមនុស្សា នោះបងនឹងប្រើពលសេនាដណ្ដើមឲ្យបានជ័យជំនះ តែនេះគឺជាយក្សាដែលមានរឹទ្ធិខ្លាំងក្លាណាស់នរណានឹងអាចតទល់បាន"។

ព្រះនាងកេសរសុមន្ទាស្ដាប់បន្ទូលព្រះរាមហើយ ទ្រង់ព្រះកន្សែងរៀបរាប់ដល់បិតាថា: ឱបិតា បើព្រះអង្គគង់នៅ ទ្រង់ថ្នាក់ថ្នមបុត្រីមិនឲ្យមានហ្មងទេ ពេលនេះឥតពីបិតាឥតមាននរណាមេត្តាបុត្រទេ សូមបិតាយកបុត្រីទៅផង។

អត្ថបទដោយ៖ កញ្ញា មាស សុភាព

ព្រះអង្គសេនាកុត្តរាជយល់អនុជសោយសោកដូច្នោះ ទ្រង់ត្រាស់ថា: "ហៃប្អូនឧត្តម នាងកុំសោយសោកាថ្វី ចាំបងជូនប្អូនទៅ បងមិនហ៊ានឃាត់ប្អូនទេ ឥតពីបិតាទៅ មានបងស្មើនឹងឪពុក បើសត្រូវចង់មកបៀតបៀន មិនថាយក្ស ឬមនុស្សទេបងនឹងច្បាំងឲ្យអស់ពីកាយចិត្ត..."។ មានបន្ទូលរួចទ្រង់ត្រាស់បញ្ជាទៅអាមាត្យថា: "ចូរទៅប្រាប់អស់មន្ត្រីឲ្យរៀបពល ត្បិតអញនឹងចេញទៅស្រះស្រង់ ឧទ្យានក្នុងថ្ងៃនេះ"។ អាមាត្យស្តាប់ហើយក៏ក្រាបបង្គំលាចេញទៅប្រាប់អស់មន្ត្រីឲ្យរៀបចំប្រដាប់ប្រដាពលសេនា ត្បិតស្តេចនឹងចេញទៅស្រះស្រង់ឧទ្យាននាយនាថ្ងៃនេះ។

លុះរៀបចំរួបហើយ ក៏យាងស្តេចទាំងពីរអង្គមកដើម្បីចេញដំណើរ។ ព្រះអង្គសេនាកុត្តរាជគង់លើគជសារមង្គល ចំណែកឯកេសរសុមទ្នាគង់ក្នុងប្រាសាទមាសហែរហមដោយពលសេនាយោធាជាច្រើន ចេញពីនគរសំដៅស្រះស្រង់ឧទ្យាននាយ...។ ក្នុងកាលនោះដែរមានយក្សមួយឈ្មោះថា កុម្ភ័ណ្ឌ រស់នៅក្នុងព្រៃហេមពាន្ត។ កុម្ភ័ណ្ឌមានមាឌធំអស្ចារ្យណាស់ មានរឹទ្ធិខ្លាំងក្លាពេកក្រៃ រស់នៅក្នុងប្រាសាទយ៉ាងល្អស្អាតតែមួយអង្គឯង ឥតមានបុត្រភរិយាអ្វីឡើយ...។ កុម្ភ័ណ្ឌតែងតែទៅបម្រើព្រះឥសូរមិនដែលខានឡើយ។ មានរាត្រីមួយ កុម្ភ័ណ្ឌគិតក្នុងចិត្តថា: "អង្គអញនេះណាមិនមានបុត្រ ឬភរិយាគ្រាន់រួមរស់ជាមួយគ្នាសោះ អញគួរតែរកស្រីស្អាតម្នាក់ មកគ្រាន់ធ្វើជាភរិយា មិនថាយក្ស កិន្នរ ឬមនុស្សាទេ គួរតែមានរូបល្អស្អាតល្មមមកធ្វើជាភរិយា..."។ យក្សគិតក្នុងចិត្តហើយក៏ចាប់ដំបងគ្រវីហោះផ្លោះផ្លោងឆ្ពង់ដល់នគរបញ្ចាល។ កាលនោះដែរ ព្រះអង្គសេនាកុត្តរាជស្តេចនាំអនុជទៅដល់ឧទ្យានស្រះស្រង់ ពេលនោះយក្សក៏បានពួនក្នុងព្រៃលបមើលព្រះនាងកេសរសុមទ្នា នឹកសរសើរក្នុងចិត្តថា: នាងនេះគួរជាភរិយាសម្លាញ់យើងហើយ...។ លុះគិតរួចស្រេចហើយ កុម្ភ័ណ្ឌ ក៏ប្រែប្រាណជាមនុស្សចូលទៅក្នុងជំនុំដោយពុំមាននរណាម្នាក់ដឹងឡើយ។ កាលនោះ សេះដែលជាយានជង្គ្លើបានធំក្លិនយក្សក៏ស្រែកកងរំពងពេញព្រៃ។ ព្រះអង្គសេនាកុត្តរាជយល់ហេតុការណ៍ដូច្នោះក៏ត្រាស់សួរថា:

អត្ថបទដោយ៖ កញ្ញា មាស សុភាព

"ហៃអាមាត្យមន្ត្រី តើមានហេតុការណ៍អ្វី បានជាសេះស្រែកយ៉ាងដូច្នេះ?"។ មន្ត្រីទូលស្ដេចវិញថា: "បពិត្រព្រះអង្គ នេះសមមានហេតុភេទហើយ សូមព្រះអង្គហៅហោរគន់គូរមើលរាសីក្នុងពេលនេះទៅព្រះអង្គ"។ ព្រះអង្គសេនាកុត្តរាជបានឲ្យហោរគន់មើល ហោរថា: "ត្បិតពេលនេះមានយក្សចូលក្នុងកន្ទៃងនេះ នឹងនាំយកព្រះនាងចេញពីព្រះអង្គឥឡូវនេះហើយ"។ ភ្លាមនោះដែរ កុម្ភ័ណ្ឌ ក៏បានប្រែប្រាណជាយក្សធំសម្បើម ស្ទុះទៅចាប់បីពព្រះនាងកេសរសុមន្ទាហោះចេញទៅ។ ព្រះអង្គសេនាកុត្តរាជយល់ដូច្នោះសោយសោកយ៉ាងខ្លាំងពេកក្រៃរហូតដល់សន្លប់បាត់ស្មារតី។ អស់អាមាត្យមន្ត្រីឃើញហេតុការណ៍ហើយភ្លេចភ្លាំងអស់ស្មារតី នឹកអាណិតដល់ក្សត្រីកេសរសុមន្ទា។

យើងងាកមកមើលកុម្ភ័ណ្ឌវិញម្ដង កាលដែលហោះនាំកេសរសុមន្ទាមកនោះ ធ្វើឲ្យព្រះនាងភិតភ័យរហូតសន្លប់បាត់ស្មារតី។ កុម្ភ័ណ្ឌបានបីថ្នមក្សត្រីយកទៅដាក់លើក្រឡាបន្ទំ...។

**(សូមរង់តាមដានរឿង ស័ង្ខសិល្បជ័យ ភាគទី២ នៅសប្ដាហ៍ក្រោយ)**

អត្ថបទដោយ៖ កញ្ញា មាស សុភាព